01389382

Declassified to Public
28 October 2021

E234

នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០៣/០៧-០៩-២០០៩-អវតក/កសចស |
| ដាក់ទៅ | : | សហចៅក្រមស៊ើបអង្កេត |
| ថ្ងៃដាក់ | : | ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៧ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| ភាសាដើម | : | អង់គ្លេស |

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 09 / 02 / 2017
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SAMN RADA

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សម្ងាត់ អមដោយ ឧបសម្ពន្ធសម្ងាត់១**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយ កសចស:

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរដើម្បីដាក់សម្ភារៈនៅក្នុងសំណុំរឿង០០៣**

---

**អ្នកដាក់ឯកសារ:**
សហព្រះរាជអាជ្ញាអន្តរជាតិ
លោក Nicholas KOUMJIAN

**ចម្លងជូន:**
សហព្រះរាជអាជ្ញាជាតិ
លោកស្រី ជា លាង

**អ្នកទទួលឯកសារ:**
សហចៅក្រមស៊ើបអង្កេត
ចៅក្រម យូ ប៊ុនឡេង
ចៅក្រម Michael BOHLANDER

គ្រប់ដើមបណ្តឹងរដ្ឋប្បវេណី
ក្នុងសំណុំរឿង០០៣ ទាំងអស់

ជនត្រូវចោទ
មាស មុត
លោក អាង ឧត្តម
លោក Michael KARNAVAS

## I. សេចក្តីផ្តើម

1. អនុលោមតាមវិធានផ្ទៃក្នុង[1] ៦៦(១)[2] និង៥៥(១០) សហព្រះរាជអាជ្ញាអន្តរជាតិ ("សហព្រះរាជអាជ្ញា") ស្នើសុំឱ្យ សហចៅក្រមស៊ើបអង្កេត ("សចស") ដាក់សម្ភារៈដែលមានរៀបរាប់នៅក្នុង **ឧបសម្ព័ន្ធ** ក ទៅលើសំណុំរឿង០០៣។ សម្ភារៈទាំងអស់នេះពាក់ព័ន្ធផ្ទាល់ទៅនឹងការចោទប្រកាន់នានានៅក្នុងសំណុំរឿង០០៣។ សហព្រះរាជអាជ្ញាយល់ឃើញថា ស្របតាមយុត្តិសាស្ត្រជាធរមាន សំណើនេះ មានភាពត្រឹមត្រូវគ្រប់គ្រាន់ និងពន្យល់ពីមូលហេតុដែលកិច្ចនេះ មានតម្លៃពាក់ព័ន្ធ *ជាបឋម* ទៅនឹងការបញ្ជាក់ការពិត[3] នៅក្នុងវិសាលភាពនៃការស៊ើបអង្កេតអនុលោមតាមដែនកំណត់ និងលក្ខខណ្ឌកម្រិតដែលកំណត់ដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមនៃសំណុំរឿង០០៣[4]។

## II. ប្រវត្តិនីតិវិធី

2. កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ បានចាប់ផ្តើមនៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩ ដោយការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីររបស់សហព្រះរាជអាជ្ញា[5]។ នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ សហព្រះរាជអាជ្ញាបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងស៊ើបសួរបន្ថែម[6]។

---

[1] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, វិធានផ្ទៃក្នុង (វិ.៩), វិសោធនកម្មថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ("វិធានផ្ទៃក្នុង" ឬ "វិធាន")។

[2] យោងតាមវិធាន ៦៦(១) "ភាគីទាំងអស់មានរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ ដើម្បីសុំឱ្យមានកិច្ចស៊ើបសួរបន្ថែម"។ នៅក្នុង **D225** សេចក្តីជូនដំណឹងអំពីការបិទការស៊ើបសួរប្រឆាំង មាស មុត, ១០ មករា ២០១៧ ("សេចក្តីជូនដំណឹងស្តីពីការបិទ"), កថាខណ្ឌ ៤, ៧, សចសអ បន្ថែមរយៈពេលនេះដល់ ៣០ ថ្ងៃ។

[3] ដូចដែលតម្រូវដោយវិធានផ្ទៃក្នុង និងអង្គបុរេជំនុំជម្រះ។ *សូមមើល* វិធាន៥៥(១០) និង ៥៨(៦)។ សំណុំរឿង០០២-**D365/2/17** សាលដីកាស្តីពីការពិចារណាឡើងវិញ ទៅលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសំណើសុំដាក់បញ្ចូលឯកសារភ័ស្តុតាងបន្ថែមទៅក្នុងសំនុំរឿង ដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទ ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង, ២៧ កញ្ញា ២០១០ ("សាលដីកាស្តីពីការពិចារណាឡើងវិញ"), កថាខណ្ឌ៤៧-៤៨, ៥០។ សំណុំរឿង០០២-**D164/4/13** សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច លើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុករួម, ១៨ វិច្ឆិកា ២០០៩, កថាខណ្ឌ៤៤។ សំណុំរឿង០០២-**D164/3/6** សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច លើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុករួម, ១២ វិច្ឆិកា ២០០៩, កថាខណ្ឌ៤៣។

[4] សំណុំរឿង០០២-**D365/2/17** សាលដីកាស្តីពីការពិចារណាឡើងវិញ, កថាខណ្ឌ៤៩។

[5] **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី២ របស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងកងទ័ពបដិវត្តកម្ពុជា ចុះថ្ងៃទី២០-១១-២០០៨ ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ"); **D1/1** សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទីអំពីការដាក់

3. នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("សចសអ") បានជូនដំណឹង មាស មុត ថាមានភស្តុតាងច្បាស់លាស់ និងស៊ីចង្វាក់បង្ហាញថា គាត់អាចទទួលខុសត្រូវចំពោះ ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តរវាងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩[7]។ មាស មុត ត្រូវបានចោទប្រកាន់អំពីការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ តាមរយៈទម្រង់ជាច្រើននៃការ ទទួលខុសត្រូវ ដោយរួមមានតាមរយៈការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម ("JCE")[8]។ សចសអ បានកំណត់គោលនយោបាយ បកក ចំនួនបួន ដែលត្រូវបានអនុវត្តដោយសមាជិករបស់ JCE តាម រយៈការប្រព្រឹត្តឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ទាំងនេះ៖ (១) ការបង្កើត និងដំណើរការ "សហករណ៍" និងការដ្ឋានពលកម្មដោយបង្ខំ (២) "ការកសាង" "សមាសភាពមិនល្អ" និងការ សម្លាប់ "ខ្មាំង" ទាំងនៅក្នុងជួរកងទ័ព ទាំងនៅក្រៅជួរកងទ័ព (៣) ការដាក់មុខសញ្ញាលើក្រុមជាក់ លាក់នានា ជាពិសេស ជនជាតិវៀតណាម និងថៃ ឬជនដែលមានសញ្ជាតិវៀតណាម និងថៃ (ពិតប្រាកដ ឬគ្រាន់តែគេយល់ឃើញថាជនជាតិ/សញ្ជាតិវៀតណាម និងថៃ) រាប់បញ្ចូលទាំង ទាហាន ឬអតីតទាហាន ជនស៊ីវិល និងជនបរទេសដែលធ្វើដំណើរនៅក្នុងដែនដីកម្ពុជាប្រជាធិប តេយ្យ និង (៤) ការរៀបចំអាពាហ៍ពិពាហ៍ឱ្យជនស៊ីវិល និងសមាជិក "ក.ប.ក" ដោយបង្ខំ[9]។

4. នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៦ សចសអ បានដាក់ចេញនូវនីតិវិធីសម្រាប់ឱ្យសហព្រះរាជអាជ្ញា អនុវត្តតាម នៅពេលដែលស្នើសុំថា ឯកសារនានាពីសំណុំរឿង០០២ ត្រូវដាក់បញ្ចូលទៅលើសំណុំ រឿងផ្សេងទៀត[10]។ យោងតាមនីតិវិធីនោះ៖ (ក) សហព្រះរាជអាជ្ញាជាបឋមត្រូវស្វែងរកការ អនុញ្ញាតពីអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង០០២ ដើម្បីដាក់បង្ហាញឯកសារសម្ងាត់ណា មួយទៅមេធាវីការពារក្តីក្នុងសំណុំរឿងផ្សេងទៀត (ខ) ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងយល់ ព្រមផ្តល់ការអនុញ្ញាតឱ្យ សហព្រះរាជអាជ្ញាគួរផ្តល់ឯកសារទាំងនោះទៅមេធាវីការពារក្តីនៅក្នុង សំណុំរឿងផ្សេងទៀត ដើម្បីធ្វើការពិនិត្យ នៅក្រៅនីតិវិធីដាក់ឯកសារជាផ្លូវការ និង (គ) សហព្រះ

---

6 **D120** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្តីពីទីតាំងឧក្រិដ្ឋកម្មនានាទាក់ទងនឹង សំណុំរឿង០០៣, ៣១ តុលា ២០១៤ ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម").

7 **D174** កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់លោក មាស មុត, ១៤ ធ្នូ ២០១៥ ("កំណត់ហេតុនៃការបង្ហាញខ្លួនលើក ដំបូង")។

8 **D174** កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង, ទំព័រ ៤-៩។

9 **D174** កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ មាស មុត, ទំព័រ៩។

10 **D209** ដីកាសម្រេចលើសំណើរបស់ យឹម ទិត្យ សុំព័ត៌មានបន្ថែម និងឯកសារទាក់ទងនឹងសំណើរបស់សហព្រះរាជអាជ្ញា អន្តរជាតិសុំដាក់សម្ភារៈ [កោសលុប] ទៅលើសំណុំរឿង០០៤, ១៦ កញ្ញា ២០១៦ ("ដីកាសម្រេច ១៦ កញ្ញា ២០១៦"),

រាជអាជ្ញាគួរដាក់សំណើមួយទៅសហចៅក្រមស៊ើបអង្កេត ("សចស") ថាសម្ភារៈទាំងនោះ ត្រូវដាក់ក្នុងសំណុំរឿងនៅក្នុងរឿងក្តីផ្សេងនោះ[11]។

5. នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧ សចសអ បានជូនដំណឹងភាគីនានាថា រូបគាត់បានពិចារណាថា កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ បានត្រូវបញ្ចប់ហើយ[12] និងបានផ្តល់ពេលវេលាចំនួន៣០ថ្ងៃ ឱ្យដាក់សំណើសុំបំពេញកិច្ចស៊ើបសួរណាមួយ[13]។ នៅថ្ងៃដូចគ្នានោះដែរ សចសអ បានចេញដីកាសម្រេចរបស់ខ្លួន កាត់បន្ថយវិសាលភាពកិច្ចស៊ើបសួរអនុលោមតាមវិធាន ៦៦*ស្ទួន* នៃវិធានផ្ទៃក្នុង[14]។

6. អនុលោមតាមនីតិវិធីរបស់ សចសអ ដែលបានគូសបញ្ជាក់ខាងលើ[15] សហព្រះរាជអាជ្ញាបានដាក់សំណើសុំចំនួនពីរទៅអង្គជំនុំជម្រះសាលាដំបូង នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧ ("សំណើទីមួយ")[16] និងថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៧ ("សំណើទីពីរ")[17] សុំការអនុញ្ញាតដាក់បង្ហាញឯកសារទាំងអស់នោះ ក្នុង**ឧបសម្ព័ន្ធ ក** ទៅមេធាវីការពារក្តី មាស មុត ដែលបច្ចុប្បន្នត្រូវបានចាត់ថ្នាក់ថា

---

[11] **D209** ដីកាសម្រេច ១៦ កញ្ញា ២០១៦, កថាខណ្ឌ ១២-១៤, ១៨៖ "ឯកសារទាំងនោះគួរតែត្រូវបានផ្តល់ជូនជាមុន និងក្នុងលក្ខណៈសម្ងាត់ទៅកាន់មេធាវីការពារក្តី សម្រាប់ជាយោបល់របស់ពួកគេនៅក្រៅនីតិវិធីដាក់ឯកសារផ្លូវការសម្រាប់សំណើសុំបំពេញកិច្ចស៊ើបសួរពិតប្រាកដ។ សពអ បន្ទាប់មកនឹងត្រូវបញ្ជាក់នៅក្នុងសំណើសុំបំពេញកិច្ចស៊ើបសួររបស់ខ្លួនថា សំណៅជាមុនបែបនោះត្រូវបានប្រគល់ជូន និងនៅពេលវេលានោះ។ ១៣. ហេតុដូច្នេះ ក្នុងករណីនេះ ខ្ញុំនឹងណែនាំ សពអ ឱ្យផ្តល់ទៅឱ្យមេធាវីការពារក្តីនូវសំណៅសម្ងាត់នៃឯកសារដែលរៀបរាប់នៅក្នុងឧបសម្ព័ន្ធរបស់មេធាវីការពារក្តី នៅក្នុងភាសាដែលស្នើសុំនៅក្នុងនោះ ក្នុងទម្រង់ណាក៏ដោយដែលគាត់ជ្រើសរើស ថាតើវាជាសំណៅចម្លងរឹង ឬអេឡិចត្រូនិក។ ១៤. នីតិវិធីនេះគួរត្រូវបានអនុវត្តនៅទូទាំងសំណុំរឿងទាំងអស់ និងសម្រាប់សំណើនាពេលអនាគតពីភាគីណាមួយផងដែរ។ ដូច្នេះ ខ្ញុំនឹងបង្គាប់ថា សំណៅកោសលុបនៃដីកាសម្រេចនេះត្រូវដាក់លើសំណុំរឿង០០៣... ១៨. ណែនាំឱ្យ សពអ ផ្តល់ឱ្យមេធាវីការពារក្តីនូវសំណៅសម្ងាត់នៃឯកសារ [...] បន្ទាប់ពីបានស្វែងរកការអនុញ្ញាតពីអង្គជំនុំជម្រះដើម្បីធ្វើដូច្នេះ ប្រសិនបើចាំបាច់"។

[12] **D225** សេចក្តីជូនដំណឹងស្តីពីការបិទ។

[13] **D225** សេចក្តីជូនដំណឹងស្តីពីការបិទ, កថាខណ្ឌ ៤, ៧។

[14] **D226** ដីកាសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរយោងតាមវិធានផ្ទៃក្នុង ៦៦*ស្ទួន*, ១០ មករា ២០១៧។

[15] សូមមើល *យោងខាងលើ* កថាខណ្ឌ ៤។

[16] **E442/2** សំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិសុំការអនុញ្ញាតដើម្បីផ្តល់ឯកសារសម្ងាត់នៃសំណុំរឿង០០២ ជូនមេធាវីការពារក្តីនៃសំណុំរឿង០០៣, ១៦ មករា ២០១៧ ("សំណើទីមួយ")។

[17] **E442/3** សំណើបន្ទាន់លើកទីពីររបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំការអនុញ្ញាត ដើម្បីផ្តល់ឯកសារសម្ងាត់នៃសំណុំរឿង

"សម្ងាត់" នៅលើសំណុំរឿង០០២។ សំណើទីមួយទទួលបានការអនុញ្ញាតនៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧[18] ហើយសំណើទីពីរទទួលបានការអនុញ្ញាតនៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៧[19]។

## III. សំណើ

7. សហព្រះរាជអាជ្ញាស្នើថា សចស ដាក់ឯកសារខាងក្រោមទៅក្នុងសំណុំរឿង០០៣៖

ក. ឯកសារ ផែនទី និងវីឌីអូនៃសំណុំរឿង០០២ និង

ខ. ឯកសារសហកាលដែលជាបញ្ជីឈ្មោះ ស-២១ សំខាន់ របស់ សចសអ[20] ("បញ្ជីឈ្មោះ ស-២១ របស់ សចសអ") (មួយចំនួននៃឯកសារទាំងនោះមាននៅលើសំណុំរឿង០០២)

(រួមគ្នាហៅថា "សម្ភារៈ")។

8. នៅក្នុងការរៀបរាប់ទូលំទូលាយនេះ សម្ភារៈទាំងនោះត្រូវបានបែងចែកជាប្រាំពីរក្រុម។ ខណៈដែលឯកសារមួយចំនួន អាចពាក់ព័ន្ធលើសពីមួយក្រុមនោះ វាត្រូវបានរួមបញ្ចូលនៅក្នុងផ្នែកនៃឧបសម្ព័ន្ធ ដែលវាជាប់ពាក់ព័ន្ធខ្លាំងបំផុត។ សម្ភារៈទាំងអស់ពាក់ព័ន្ធផ្ទាល់ទៅនឹងការបញ្ជាក់ការពិតអំពីឧក្រិដ្ឋកម្មដែលគ្របដណ្ដប់ក្នុងដីការសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនឱ្យស៊ើបសួរបន្ថែមនៃសំណុំរឿង០០៣។ ភាពពាក់ព័ន្ធនៃក្រុមនីមួយៗត្រូវបានសង្ខេបខ្លីៗខាងក្រោមនេះ ហើយឯកសារ ឬវីឌីអូនីមួយៗ ត្រូវបានកំណត់អត្តសញ្ញាណ និងរៀបរាប់ជាលម្អិតបន្ថែមទៀត នៅក្នុង **ឧបសម្ព័ន្ធ ក** ដែលភ្ជាប់ជាមួយ។

9. សម្រាប់ឯកសារ ឬវីឌីអូនីមួយៗ ដែលរៀបរាប់នៅក្នុង **ឧបសម្ព័ន្ធ ក** មានផ្ដល់ជូននូវព័ត៌មានខាងក្រោមនេះ ៖ (i) លេខឯកសារសំណុំរឿង០០២ របស់វា ត្រង់ចំណុចណាដែលពាក់ព័ន្ធ និង/ឬភាពអាចរកបាននៅក្នុងឃ្លាំងផ្ទុករួម ("SMD") (ii) ថាតើវាត្រូវបានចាត់ថ្នាក់ជាសម្ងាត់ "C" ឬសាធារណៈ "P" ក្នុងសំណុំរឿង០០២ (iii) កាលបរិច្ឆេទរបស់វា (iv) ចំណងជើងរបស់វា (v) លេខយោងភស្តុតាង "ERN" សម្រាប់សំណៅជាភាសាខ្មែរ អង់គ្លេស និងបារាំង (ដូចដែលអាចរក

---

[18] **E442/2/1** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ស្ដីពី "សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំការអនុញ្ញាតផ្ដល់ឯកសារសម្ងាត់ពីសំណុំរឿង០០២ ដល់មេធាវីការពារក្ដី មាស មុត ក្នុងសំណុំរឿង០០៣", ២៦ មករា ២០១៧។

[19] **E442/3/1** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ស្ដីពី "សេចក្ដីសម្រេចលើសំណើលើកទីពីររបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំការអនុញ្ញាតផ្ដល់ឯកសារសម្ងាត់ពីសំណុំរឿង០០២ ដល់មេធាវីការពារក្ដី មាស មុត ក្នុងសំណុំរឿង០០៣", ៧ កុម្ភៈ ២០១៧ ("ការអនុញ្ញាតលើកទីពីរ")។

បាន) ថាតើជាសំណៅដើម ឬជាសំណៅបកប្រែ និង (vi) ការរៀបរាប់អំពីឯកសារ ឬវីឌីអូ និងភាពពាក់ព័ន្ធរបស់វាទៅនឹងសំណុំរឿង០០៣។

*ជម្លោះប្រដាប់អាវុធអន្តរជាតិ*

10. សហព្រះរាជអាជ្ញាស្នើសុំ សចស ឱ្យដាក់ឯកសារចំនួន ១៦ (*សម្ភារៈ ១ ដល់ ១៦*) ទៅក្នុងណុំរឿង ០០៣ ទាក់ទងនឹងជម្លោះប្រដាប់អាវុធអន្តរជាតិ។ ឯកសារទាំងនេះរួមមាន៖ (i) សេចក្ដីរាយការណ៍ សេចក្ដីថ្លែងការណ៍ជាសាធារណៈ និងឯកសារទំនាក់ទំនងផ្ទៃក្នុងសហកាលរបស់បក្សកុម្មុយនីស្ដកម្ពុជា (“បកក”) (ii) សេចក្ដីថ្លែងការណ៍ដែលចេញដោយរដ្ឋាភិបាលវៀតណាម និង (iii) សេចក្ដីរាយការណ៍ព័ត៌មានអន្តរជាតិ។ ពួកវាពាក់ព័ន្ធទៅនឹងការបង្ហាញអំពីអត្ថិភាពជម្លោះប្រដាប់អាវុធរវាងកម្ពុជាប្រជាធិបតេយ្យ (“DK”) និងប្រទេសវៀតណាម ក្នុងអំឡុងពេលរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ និងផ្ដល់នូវការចង្អុលបង្ហាញតាមភូមិសាស្ត្រ និងពេលវេលានៃការវាយប្រហារនៅតាមព្រំដែនកម្ពុជាប្រជាធិបតេយ្យ-វៀតណាម និងការប្រព្រឹត្តបទល្មើសនៅបណ្ដាកោះឯនាយសមុទ្រ រួមបញ្ចូលទាំងសកម្មភាពកងទ័ពវៀតណាមនៅលើកោះពូលូវៃ នៅពាក់កណ្ដាលឆ្នាំ១៩៧៥។ ហេតុដូច្នេះ វាពាក់ព័ន្ធ *ជាអាទិ៍* ទៅនឹងការចោទប្រកាន់នៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ប្រឆាំងនឹង មាស មុត[21] ក៏ដូចជាឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ នៅក្នុងដែនទឹក និងនៅលើកោះដែលកម្ពុជាប្រជាធិបតេយ្យទាមទារ[22] រួមទាំង ការចោទប្រកាន់នៃអំពើប្រល័យពូជសាសន៍ប្រឆាំងនឹង មាស មុត នៅក្នុងនោះផងដែរ[23]។

*គោលនយោបាយ បកក*

11. សហព្រះរាជអាជ្ញាស្នើថា សចស ដាក់ឯកសារចំនួន ២៦ និងខ្សែវីឌីអូចំនួនមួយ (*សម្ភារៈ ១៧ ដល់ ៤៣*) ទៅលើសំណុំរឿង០០៣ ទាក់ទងនឹងគោលនយោបាយ បកក។ សម្ភារៈទាំងអស់នេះរួមមាន សេចក្ដីថ្លែងការណ៍ និងឯកសារបោះពុម្ពផ្សាយសហកាលច្រើនលើសលប់របស់ បកក[24] ដែល

---

[21] **D174** កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង, ទំព័រ ៧-៨។

[22] **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, កថាខណ្ឌ៥៩-៦១។ **D174** កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង, កថាខណ្ឌ ៤, ៦, ៨។

[23] **D174** កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង, ទំព័រ៤។

បំពេញបន្ថែមដោយរបាយការណ៍វិភាគជាបន្តបន្ទាប់[25] និងកំណត់ត្រានៃសេចក្តីថ្លែងការណ៍ដែលធ្វើឡើងដោយ នួន ជា និង ខៀវ សំផន[26]។

12. ដូចបានរៀបរាប់លម្អិតនៅក្នុង **ឧបសម្ព័ន្ធ** ក សម្ភារៈទាំងនេះផ្តល់នូវភ័ស្តុតាងអំពីការបង្កើត ការវិវឌ្ឍន៍ និងការអនុវត្តគោលនយោបាយទាំងបួនរបស់ បកក[27] មកដល់រយៈពេល ឬក្នុងអំឡុងរយៈពេលស្ថិតក្រោមការស៊ើបអង្កេតក្នុងសំណុំរឿង០០៣។ វាបង្ហាញអំពីសារដែលត្រូវបានបញ្ជូននៅទូទាំងរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីធានាឲ្យបាននូវការអនុវត្តដូចគ្នាទាំងអស់ នូវគោលនយោបាយនានាក្នុងកងពលធំ ភូមិភាគ តំបន់ ស្រុក និងឃុំជាច្រើន និងដើម្បីបញ្ជាក់អំពីគោលការណ៍គោរពដាច់ខាតចំពោះសេចក្តីសម្រេចនានារបស់ថ្នាក់លើ។ សំខាន់នោះ គឺវាបង្ហាញពីចរិតជាប្រព្រឹត្តទៅដែលជាប់មកជាមួយក្នុងការអនុវត្តពិតប្រាកដ ឬដោយចេតនា នូវគោលនយោបាយទាំងនេះនៅទូទាំងរបបកម្ពុជាប្រជាធិបតេយ្យ។ ហេតុដូច្នេះ សម្ភារៈទាំងនេះពាក់ព័ន្ធក្នុងការបង្ហាញអំពីអត្ថិភាព វិសាលភាព និងគោលបំណងនានានៃផែនការឧក្រិដ្ឋកម្មរួម និងគឺជាចំណុចសំខាន់ចំពោះបញ្ហានៃការទទួលខុសត្រូវរបស់ មាស មុត លើឧក្រិដ្ឋកម្មដែលគ្របដណ្តប់ដោយដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។

13. ផ្នែកពិតប្រាកដនៃភ័ស្តុតាងបង្ហាញអំពីខ្មាំងគោលនយោបាយ ទាំងខាងក្នុង និងខាងក្រៅកងទ័ព និងការដាក់មុខសញ្ញាលើក្រុមជាក់លាក់ រួមមានជនជាតិវៀតណាម ឬអ្នកទាំងឡាយណាដែលមានទំនាក់ទំនងទៅនឹងជនជាតិវៀតណាម ក៏មានការពាក់ព័ន្ធខ្លាំងទៅនឹងចេតនាប្រល័យពូជសាសន៍ និងការធ្វើទុក្ខបុកម្នេញជាក់លាក់របស់ មាស មុត និងសហចារីរបស់គាត់ផងដែរ។

14. សហព្រះរាជអាជ្ញាដឹងអំពីភ័ស្តុតាងដែលមានរួចហើយនៅក្នុងសំណុំរឿង០០៣ និងដឹងថាមានលេខចេញផ្សាយជាច្រើនហើយនៃទស្សនាវដ្តី*ទង់បដិវត្ត និងយុវជនយុវនារីបដិវត្ត* នៅលើសំណុំរឿង ក៏ដូចជាឯកសារផ្សេងទៀតទាក់ទងនឹងគោលនយោបាយ។ ប៉ុន្តែ នៅពេលដែលភ័ស្តុតាងថ្មី

---

[25] *សម្ភារៈ* ២២,៣៦, ៣៩, ៤១។

[26] *សម្ភារៈ* ៣២, ៣៣, ៣៥, ៣៨, ៤០, ៤២, ៤៣។

[27] ដូចមានចែងនៅក្នុង*យោងខាងលើ,* កថាខណ្ឌ៣ មានគោលនយោបាយ បកក ចំនួនបួន គឺៈ(១) ការបង្កើត និងដំណើរការ "សហករណ៍" និងការដ្ឋានពលកម្មដោយបង្ខំ (២) "ការកសាង" "សមាសភាពមិនល្អ" និងការសម្លាប់ "ខ្មាំង" ទាំងនៅក្នុងជួរកងទ័ព ទាំងនៅក្រៅជួរកងទ័ព (៣) ការដាក់មុខសញ្ញាលើក្រុមជាក់លាក់នានា ជាពិសេស ជនជាតិវៀតណាម និងថៃ ឬជនដែលមានសញ្ជាតិវៀតណាម និង ថៃ (ពិតប្រាកដ ឬគ្រាន់តែគេយល់ឃើញថាជនជាតិ/សញ្ជាតិវៀតណាម និងថៃ) រាប់បញ្ចូលទាំងទាហាន ឬអតីតទាហាន ជនស៊ីវិល និងជនបរទេសដែលធ្វើដំណើរនៅក្នុងដែនដីកម្ពុជាប្រជាធិបតេយ្យ និង (៤) ការរៀប

ដែលបានស្នើឡើងនោះត្រូវបានពិនិត្យមើលស្របគ្នាជាមួយនឹងឯកសារដែលមាននៅលើសំណុំរឿង ០០៣ វាផ្តល់នូវរូបភាពកាន់តែច្បាស់ថែមទៀតអំពីគោលនយោបាយទាំងបួន ពីប្រភពដើមរបស់វា និងដូចដែលវាវិវឌ្ឍន៍នៅទូទាំងរបបកម្ពុជាប្រជាធិបតេយ្យ។ ការរៀបរាប់ជាលទ្ធផល មានសារៈសំខាន់ចំពោះការយល់ដឹងអំពីស្ថានភាព នៅទូទាំងប្រទេសនៅពេលជាក់លាក់ណាមួយដែលបានផ្តល់ជូន ខណៈដែលព្រឹត្តិការណ៍នានានៅក្នុងសហករណ៍ ការដ្ឋាន និងមន្ទីរសន្តិសុខ បានផ្តុះបញ្ចាំងឲ្យឃើញអំពីគោលនយោបាយដែលបានផ្សព្វផ្សាយនៅក្នុងសម្ភារៈទាំងអស់នេះ។ ទោះបីជាមានខ្លឹមសាររួមនៅទូទាំងភស្តុតាងបន្ថែមនេះក៏ដោយ ក៏ផ្នែកនីមួយៗផ្តល់ព័ត៌មានលម្អិតពិសេសអំពីគោលនយោបាយ ដែលមិនអាចរកបាននៅកន្លែងផ្សេងទៀត។ ជាងនេះទៀត សម្ភារទាំងនេះគឺជាការប្រកាសដាច់ខាតពីថ្នាក់លើបំផុត ដែលពាក់ព័ន្ធផ្ទាល់ទៅនឹងទ្រង់ទ្រាយនៃគោលនយោបាយទាំងបួន នៅក្នុងចំណុចសំខាន់បំផុតនៃកិច្ចស៊ើបសួររបស់សំណុំរឿង០០៣។

*ការប្រាស្រ័យទាក់ទង*

15. សហព្រះរាជអាជ្ញាស្នើសុំការដាក់បន្ថែមឯកសារចំនួន ១៤ (*សម្ភារៈ ៤៤ ដល់ ៥៧*) ពាក់ព័ន្ធនឹងការប្រាស្រ័យទាក់ទងផ្ទៃក្នុងរបស់ បកក ទៅក្នុងសំណុំរឿង០០៣។ ទាំងអស់នេះ គឺជារបាយការណ៍ និងទូរលេខជាច្រើនដែលបានបញ្ជូនរវាងកងពលធំ និងអគ្គសេនាធិការ ជាពិសេស សុន សេន[28]។ វាពាក់ព័ន្ធសម្រាប់ការបង្ហាញអំពីរចនាសម្ព័ន្ធនៃការរាយការណ៍នៅក្នុង កបក និងការផ្សព្វផ្សាយនៅក្នុង កបក នូវគោលនយោបាយដែលបានអនុម័តដោយមជ្ឈិមបក្ស ក៏ដូចជាការអនុវត្តវិន័យរបស់បក្ស ការត្រួតពិនិត្យយ៉ាងស្និទ្ធរបស់កម្មាភិបាលយោធា ការកំណត់អត្តសញ្ញាណ ការកសាង និងការបោសសម្អាតខ្មាំងផ្ទៃក្នុងដែលគេសន្មតនៅក្នុង កបក និងការចាប់ខ្លួន និងការសម្លាប់ខ្មាំងខាងក្រៅ។ ទោះបីជា ក្នុងករណីខ្លះ របាយការណ៍ និងទូរលេខទាំងនេះពាក់ព័ន្ធនឹងកងពលធំរបស់ កបក ជាជាងពាក់ព័ន្ធផ្ទាល់ទៅនឹងសំណុំរឿង០០៣ ក៏ដោយ ក៏វាពាក់ព័ន្ធខ្លាំងទៅនឹងការបង្ហាញអំពីទ្រង់ទ្រាយនៃទម្រង់ និងសារធាតុនៃការប្រាស្រ័យទាក់ទងទៅវិញទៅមករវាងកងពលធំ និងអគ្គសេនាធិការ ហើយដែលនឹងត្រូវបានអនុវត្តតាមក្នុងការប្រាស្រ័យទាក់ទងស្រដៀងគ្នានេះ ពាក់ព័ន្ធនឹង មាស មុត ជាពិសេសទាក់ទងនឹងខ្មាំងខាងក្នុង និងខ្មាំងខាងក្រៅ។

16. ឯកសារទាំងនេះមួយចំនួនតូច[29] គឺជាឯកសារប្រាស្រ័យទំនាក់ទំនងផ្ទៃក្នុងរបស់អគ្គបញ្ជាការកងទ័ព ដែលពិភាក្សាអំពីការកសាងខ្លួន និងការបោសសម្អាតខ្មាំងចេញពីជួរកងទ័ពបដិវត្តកម្ពុជា។

---

[28] សូមមើល *សម្ភារៈ ៤៤, ៤៦-៤៩, ៥១*។

ឯកសារទាំងនេះមានការពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងការកំណត់*ជាអាទិ៍* ការចាប់ខ្លួន និងការសម្លាប់មនុស្សក្នុងការបោសសម្អាតកងទ័ពបដិវត្តកម្ពុជា ដែលបានកើតឡើងស្របតាមសេចក្ដីណែនាំរបស់អគ្គបញ្ជាការកងទ័ព និងមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា។

17. អ្វីដែលបានដាក់បញ្ចូលទៅក្នុងវាក្យខណ្ឌនេះនៃ **ឧបសម្ព័ន្ធ** ក ផងដែរនោះ គឺឯកសារមួយចំនួនទៀត (សម្ភារ: ៥៣ ដល់ ៥៦) ដែលមានដើមកំណើតចេញពីក្រុមប្រឹក្សាជាតិសហរដ្ឋអាមេរិក ក្នុងខែឧសភា ឆ្នាំ១៩៧៥ ដែលពាក់ព័ន្ធនឹងការវាយប្រយុទ្ធគ្នារវាងវៀតណាម និងកម្ពុជា នៅតាមកោះជាច្រើនក្នុងខែមេសា-ឧសភា ឆ្នាំ១៩៧៥ និងឧប្បត្តិហេតុកប៉ាល់ម៉ាយ៉ាគេស្ស (Mayaguez)។ ឯកសារទាំងនេះមានការពាក់ព័ន្ធលើបញ្ហាជាច្រើននៃសំណុំរឿង០០៣ រួមទាំងការបង្ហាញអំពីអត្ថិភាពជម្លោះប្រដាប់អាវុធអន្តរជាតិរវាងវៀតណាម និងកម្ពុជាប្រជាធិបតេយ្យ និងស្ថានភាពនៅតាមកោះនានាដែលទាមទារដោយរដ្ឋទាំងពីរ ក្នុងខែឧសភា ឆ្នាំ១៩៧៥[30]។ លើសពីនេះឯកសារក៏ពាក់ព័ន្ធនឹងការកំណត់អំពីការស្លាប់អ្នកទោសដែលជាប់នៅលើបណ្ដាកោះនានា និងនៅមន្ទីរសន្តិសុខវត្តអង្គតាញាណ នៅក្រោមកណ្ដាប់ដៃរបស់កងពលធំ១៦៤[31]។

18. ជាចុងក្រោយ កំណត់ហេតុនៃការវិភាគជាលាយលក្ខណ៍អក្សរដោយ Graig Etcheson (*សម្ភារ:* ៥៧) ផ្ដល់ទិដ្ឋភាពយ៉ាងច្បាស់អំពីរចនាសម្ព័ន្ធសិទ្ធិអំណាច បុគ្គលិក និងការប្រាស្រ័យទំនាក់ទំនងរបស់កម្ពុជាប្រជាធិបតេយ្យ និយាយឱ្យចំគឺការពាក់ព័ន្ធទៅនឹងគណៈកម្មាធិការយោធាមជ្ឈិមបក្ស អគ្គបញ្ជាការ កងពលធំ និងកងវរសេនាធំឯករាជ្យរបស់កងទ័ពបដិវត្តកម្ពុជា[32]។ អង្គការលេខនៃរចនាសម្ព័ន្ធនេះ គឺជាមូលដ្ឋាននៃការយល់ដឹងអំពីរចនាសម្ព័ន្ធឋានានុក្រមដែល មាស មុត និងកងពលធំ១៦៤ គឺជាផ្នែកមួយ[33]។ ឯកសារនេះក៏វិភាគអំពីការទទួលខុសត្រូវរបស់យោធាចំពោះបញ្ហាសេដ្ឋកិច្ច និងសន្តិសុខខាងក្នុង និងខាងក្រៅ ការគូសបញ្ជាក់អំពីការប្រាស្រ័យទំនាក់ទំនងនៃគោលនយោបាយ បកក នៅក្នុងជួរយោធា និងការផ្ដល់ភ័ស្តុតាងអំពីការបោសសម្អាតផ្ទៃក្នុងផងដែរ[34]។

---

[30] សូមមើល *ខាងដើម* កថាខណ្ឌ១០។

[31] **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, កថាខណ្ឌ៥៥-៥៧, ៥៩-៦១។ **D174** កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង, ទំព័រ៥, ៦ និង៨។

[32] សូមមើល ជាពិសេស, **E3/494** កំណត់ហេតុនៃការវិភាគជាលាយលក្ខណ៍អក្សរដោយ Craig C. Etcheson, អ្នកស៊ើបអង្កេតនៃការិយាល័យសហព្រះរាជអាជ្ញា, ១៨ កក្កដា ២០០៧ ("កំណត់ហេតុនៃការវិភាគជាលាយលក្ខណ៍អក្សរ"), កថាខណ្ឌ ២៤-៣១, EN 00142849-00142856។

[33] សម្រាប់ការយោងជាក់លាក់ទៅរក មាស មុត, សូមមើល **E3/494** កំណត់ហេតុនៃការវិភាគជាលាយលក្ខណ៍អក្សរ, កថាខណ្ឌ ២៧, ២៨, ៣១, 31, EN 00142852, 00142853, 00142856។

## *ស-២១*

19. សហព្រះរាជអាជ្ញាសូមស្នើឱ្យបញ្ចូលឯកសារ (*សម្ភារៈ ៥៨ ដល់ ៦២*) ដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងមន្ទីរសន្តិសុខស-២១ ដែលជាទីតាំងឧក្រិដ្ឋកម្មមួយនៅក្នុងសំណុំរឿង០០៣[35] ទៅក្នុងសំណុំរឿង០០៣។ ខណៈដែលភាពពាក់ព័ន្ធជាក់លាក់របស់ឯកសារទាំងនេះ ត្រូវបានរៀបរាប់យ៉ាងលម្អិតបន្ថែមនៅក្នុង **ឧបសម្ព័ន្ធ ក** សម្ភារៈទាំងនេះផ្តល់នូវភស្តុតាងដោយផ្ទាល់អំពីការបោសសម្អាតកម្មាភិបាលនៅក្នុងកងពលធំ១៦៤[36] ការសួរចម្លើយអ្នកទោសស-២១[37] និងការដឹងឮព្រមទាំងការពាក់ព័ន្ធរបស់ មាស មុត នៅក្នុងឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តនៅទីនោះ[38] និងការកំណត់យ៉ាងទូលំទូលាយលើសពីនេះទៀត អំពីការប្រើប្រាស់ស-២១ ធ្វើជាយន្តការនៃការបោសសម្អាតសមាជិកកងពលធំមជ្ឈិមនៃកងទ័ពបដិវត្តកម្ពុជា និងការទាក់ទងគ្នាដោយផ្ទាល់រវាងមេបញ្ជាការកងពលធំ និងប្រធានស-២១ គឺឌុច[39]។

## *ផែនទី*

20. សហព្រះរាជអាជ្ញាស្នើឱ្យបញ្ចូលផែនទី ដូចបានចុះបញ្ជីក្នុង **ឧបសម្ព័ន្ធ ក** (*សម្ភារៈ ៦៣-៦៧*) ទៅក្នុងសំណុំរឿង ដើម្បីជួយក្នុងការបង្ហាញ និងយល់ដឹងអំពីទីតាំងឧក្រិដ្ឋកម្មនានា អំពីលក្ខណៈរីករាលដាល និងជាប្រព័ន្ធ អំពីភាពជិតស្និទ្ធរបស់ មាស មុត និងអ្នកនៅក្រោមបង្គាប់របស់គាត់ទៅនឹងឧក្រិដ្ឋកម្មទាំងនោះ និងអំពីព្រំប្រទល់នៃឃុំ ស្រុក តំបន់ និងភូមិភាគដែលពាក់ព័ន្ធ។

## *ប្រតិចារឹកនៃសំណុំរឿង០០២/០២ និងសម្ភារៈពាក់ព័ន្ធ*

21. សហព្រះរាជអាជ្ញាសូមស្នើឱ្យដាក់ប្រតិចារឹកនៃសំណុំរឿង០០២/០២ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កំណត់ហេតុរបស់មជ្ឈមណ្ឌល DC-Cam, ពាក្យបណ្តឹងចំនួនមួយ និងសៀវភៅមួយក្បាលដែលបានចុះបញ្ជីក្នុងវាក្យខណ្ឌនេះនៃ **ឧបសម្ព័ន្ធ ក** (*សម្ភារៈ ៦៨ ដល់ ១០៩*) ទៅក្នុងសំណុំរឿង០០៣។

---

[35] **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, កថាខណ្ឌ៤៣, ៥២-៥៤, ៦៥-៦៦។ **D120** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម, កថាខណ្ឌ១៣-១៧។ **D174** កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង, កថាខណ្ឌ ៤ និង ៨។

[36] សម្ភារៈ ៥៩-៦០។

[37] សម្ភារៈ ៥៨-៦២។

[38] សម្ភារៈ ៥៩-៦០។

22. ដោយក្រឡេកមើលប្រតិចារឹកនៃសំណុំរឿង០០២/០២មុនគេ គឺមានប្រតិចារឹកពីរប្រភេទដែលនៅក្នុង **ឧបសម្ព័ន្ធ** ក។ ប្រភេទទីមួយ បានបញ្ចប់ហើយ និងបានផ្តល់លេខសំណុំរឿង០០២ ហើយដែរ ដោយចាប់ផ្តើមជាមួយ E1/ជាបុព្វបទ[40]។ ប្រតិចារឹកប្រភេទទីពីរ គឺអាចរកបានតែក្នុងទម្រង់ជាសេចក្តីព្រាងសម្ងាត់ប៉ុណ្ណោះ ដោយសារកំពុងស្ថិតក្រោមការពិនិត្យបញ្ចប់របស់អង្គភាពបកប្រែ[41]។ ដោយមានការគិតគូរចំពោះពេលវេលានៃការបិទកិច្ចស៊ើបសួរ សហព្រះរាជអាជ្ញាសូមស្នើថាទម្រង់សេចក្តីព្រាងនៃប្រតិចារឹកទាំងនេះអាចប្រើប្រាស់បានសម្រាប់គោលបំណងពិនិត្យ ប៉ុន្តែប្រតិចារឹកចុងក្រោយ នឹងត្រូវដាក់ទៅក្នុងសំណុំរឿងនៅពេលណាអាចរកបាន។

23. ដើម្បីការបំភ្លឺ ប្រសិនបើប្រតិចារឹកនៃថ្ងៃណាមួយមានរួចហើយនៅក្នុងសំណុំរឿង០០៣សម្រាប់គោលបំណងនៃការចងក្រងឱ្យបានឆាប់រហ័សនូវភស្តុតាងនៃសំណុំរឿង០០២/០២ របស់សាក្សី ឬដើមបណ្តឹងណាម្នាក់នោះ សហព្រះរាជអាជ្ញាមិនស្នើសុំប្រតិចារឹកដដែលជាថ្មី ដើម្បីទទួលបានភស្តុតាងពីសាក្សីផ្សេងដែលបានបំភ្លឺនៅថ្ងៃជាមួយគ្នា និងជាភស្តុតាងដែលមានរួចហើយនៅក្នុងសំណុំរឿងនោះទេ[42]។

24. មូលហេតុជាក់លាក់នៃការស្នើសុំប្រតិចារឹកសវនាការសំណុំរឿង០០២/០២ ត្រូវបានរៀបរាប់យ៉ាងលម្អិតនៅក្នុង **ឧបសម្ព័ន្ធ ក** ប៉ុន្តែជាទូទៅគឺដោយសារប្រតិចារឹកទាំងនោះ មានផ្ទុកនូវភស្តុតាងអំពីប្រធានបទនានាដូចបានគូសបញ្ជាក់ខាងលើរួចហើយ[43] ពីបណ្តាអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ដែលពួកគាត់ភាគច្រើនមានកំណត់ហេតុរបស់ពួកគាត់ ឬមានភស្តុតាងផ្សេងទៀតនៅលើសំណុំរឿង០០៣រួចហើយៗ ដែលសក្ខីកម្មរបស់ពួកគាត់ ក៏បានបញ្ជាក់បន្ថែមទៅលើភស្តុតាងនោះហើយដែរ ឬក៏អនុញ្ញាតឱ្យមានការយល់ដឹងកាន់តែប្រសើរអំពីភស្តុតាងនៅលើសំណុំរឿង។ ប្រសិនបើសហព្រះរាជអាជ្ញាពិចារណាថា ប្រតិចារឹកនៃសំណុំរឿង០០២/០២ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កំណត់ហេតុរបស់មជ្ឈមណ្ឌល DC-Cam ឬសៀវភៅនានាដែលបាននិពន្ធ

---

[40] សម្ភារៈ ៧០-៧២, ៧៥-៨៣, ៨៥-៨៧, ៨៩-៩៩, ១០២ និងផ្នែកខ្លះនៃសម្ភារៈ ១០៣, ១០៥, ១០៧, ១០៨ ។

[41] សម្ភារៈ ១០៦, ១០៩ និងផ្នែកខ្លះនៃសម្ភារៈ ១០៣, ១០៥, ១០៧, ១០៨។

[42] ជាឧទាហរណ៍ ដូចបានកត់ត្រាទុកជាកំណត់ហេតុនៅក្នុងឯកសារ **D114/297.1** ឧបសម្ព័ន្ធនៃកំណត់ហេតុនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦, ២៨ ធ្នូ ២០១៦, កសចស បានដាក់ឯកសារ **E1/489.1** ទាំងមូលទៅក្នុងសំណុំរឿង០០៣ សម្រាប់គោលបំណងនៃការធ្វើកំណត់ហេតុភស្តុតាងរបស់ ជួន ធី។ សយ ណារឿន បានផ្តល់សក្ខីកម្មក្នុងថ្ងៃតែមួយ ហើយសក្ខីកម្មរបស់នាងមាននៅក្នុងឯកសារ **E1/489.1** នេះដែរ។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាពិចារណាសក្ខីកម្មរបស់នាងថាជាផ្នែកនៃសំណុំរឿង០០៣។

[43] ជម្លោះប្រដាប់អាវុធអន្តរជាតិ, មន្ទីរសន្តិសុខ ស-២១, គោលនយោបាយនានារបស់ បកក រួមទាំងគោលនយោបាយជាក់លាក់

ដោយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះ មានផ្ទុកនូវព័ត៌មានពាក់ព័ន្ធដែលអនុញ្ញាតឱ្យមានការដាក់បញ្ចូលទៅក្នុងសំណុំរឿង០០៣ នោះនឹងមានការធ្វើកំណត់សម្គាល់ដាច់ដោយឡែកថាជាការដាក់បញ្ចូលថ្មីក្នុង **ឧបសម្ព័ន្ធ ក** ពីក្រោមកំណត់សម្គាល់ថ្មីនោះសម្រាប់សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីជាក់លាក់រូបនោះ។

25. ជាចុងក្រោយ ប្រសិនបើសហព្រះរាជអាជ្ញាបានស្នើសុំដាក់បញ្ចូលប្រតិចារឹករបស់សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីណាម្នាក់ទៅក្នុងសំណុំរឿង នោះសហព្រះរាជអាជ្ញានឹងធ្វើកំណត់សម្គាល់បន្ថែមនៅក្នុងជួរ "(សេចក្តីរៀបរាប់)" នៃ **ឧបសម្ព័ន្ធ ក** នូវរាល់កំណត់ហេតុមុនៗដទៃទៀត និងឯកសារពាក់ព័ន្ធផ្សេងទៀតទាំងអស់របស់សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីរូបនោះដែលបច្ចុប្បន្នមិនបានបង្ហាញនៅលើសំណុំរឿង០០៣។ សចស អាចមានបំណងចង់ពិនិត្យនិងបន្ថែមកំណត់ហេតុ និងឯកសារទាំងនេះទៅក្នុងសំណុំរឿង០០៣ ដើម្បីជាកិច្ចបញ្ចប់ ប៉ុន្តែនេះមិនមែនជាសំណើសុំផ្លូវការណាមួយពីសហព្រះរាជអាជ្ញាសម្រាប់ការដាក់បញ្ចូលដូច្នេះទេ។

*ឯកសារនានាជាមូលដ្ឋាននៃបញ្ជី ស-២១ របស់ កសចស*

26. សហព្រះរាជអាជ្ញាសូមស្នើដាក់ឯកសារសហកាលនៃស-២១ ចំនួន ៧៥៣ (*សម្ភារៈ១១០ ដល់ ៨៦២*) ទៅក្នុងសំណុំរឿង០០៣។

27. តាមប្រវត្តិសារតារ នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ ក្រោយការពិនិត្យទៅលើឯកសារសហកាលស-២១ រួចមក កសចស បានផលិតបញ្ជីស-២១ កសចស[44] ដែលបង្ហាញឱ្យឃើញថា មានមនុស្សចំនួន ១៥,១០១ នាក់ ត្រូវបានកត់ត្រាទុកថា ជាអ្នកទោសស-២១ ដោយផ្អែកលើឯកសារសហកាលដែលនៅសល់។ ដោយសារតួនាទីកណ្តាលរបស់ទីតាំងឧក្រិដ្ឋកម្មស-២១ ចំពោះសំណុំរឿង០០៣[45] និងវត្តមាននៅលើបញ្ជីនេះមាន*ជាអាទិ៍* ជនរងគ្រោះនៃការបោសសម្អាតកងទ័ពបដិវត្តកម្ពុជា ជាពិសេស កងពលធំ១៦៤ និង១១៧[46] និងជនជាតិវៀតណាម ថៃ និងជនជាតិមិនមែន

[44] **D114/230.1.1** បញ្ជីអ្នកទោសស-២១ របស់ កសចស, ៣០ មីនា ២០១៦។

[45] **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, កថាខណ្ឌ៤៣, ៥២-៥៤, ៦៥-៦៦។ **D120** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម, កថាខណ្ឌ១៣-១៧។ **D174** កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង, កថាខណ្ឌ ៤ និង ៨។

[46] ពាក់ព័ន្ធនឹង **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, កថាខណ្ឌ៥២-៥៤។ **D120** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម,

កម្ពុជាឯទៀត[47] ដូច្នេះភាពត្រឹមត្រូវនៃបញ្ជីស-២១ កសចស គឺមានសារៈសំខាន់លើសលប់ចំពោះភាគីនៃសំណុំរឿង០០៣។ លទ្ធភាពចូលពិនិត្យមើលឯកសារជាមូលដ្ឋាននេះ នឹងផ្ដល់ឱ្យភាគីនូវការវិភាគយ៉ាងត្រឹមត្រូវនៅលើខ្លឹមសារនៃបញ្ជីស-២១ ធៀបនឹងឯកសារសហកាលនានា ដូចបានកំណត់អត្តសញ្ញាណដោយអ្នកវិភាគ កសចស[48] ដើម្បីផ្ទៀងផ្ទាត់ មិនត្រូវតែអំពីអត្ថិភាពនៃបុគ្គលម្នាក់ៗនៅស-២១ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាគតដ្ឋាន និងមុខនាទីផង ដែលមានសារៈសំខាន់ ជាគន្លឹះក្នុងការបញ្ជាក់អំពីការពិត ទាក់ទងនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះ នៅក្នុងវិសាលភាពនៃសំណុំរឿង០០៣។

28. ឯកសារដែលបានស្នើដែលឆ្លើយតបទៅនឹងឯកសារសហកាល ស-២១ទាំងនោះ ដែលជាមូលដ្ឋាននៃបញ្ជីស-២១ កសចស ដូចដែលបានរៀបរាប់យ៉ាងលម្អិតនៅក្នុងឯកសារ **D114/230.1.2**[49] មិនទាន់បានបង្ហាញនៅក្នុងសំណុំរឿង០០៣នៅឡើយ។ ប្រសិនបើឯកសារទាំងនេះអាចឱ្យមេធាវីការពារក្ដី មាស មុត រកបានតាមរយៈឃ្លាំងផ្ទុកឯកសាររួម("SMD")ហើយនោះ នោះក៏មានបញ្ជាក់នៅក្នុងជួរ ២ និង ៣ នៃ **ឧបសម្ព័ន្ធ** ក ជាមួយលេខឯកសារសំណុំរឿង០០២ដែរ បើសិនជាចាំបាច់។ បើសិនជាឯកសារជាមូលដ្ឋានដែលពាក់ព័ន្ធ មិនអាចរកបាននៅលើ SMDទេ ហើយត្រូវបានដាក់ចំណាត់ថ្នាក់ថា "សម្ងាត់" ក្នុងសំណុំរឿង០០២ នោះសហព្រះរាជអាជ្ញាបានស្នើសុំការអនុញ្ញាតរបស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីផ្ដល់សំណៅចម្លងទៅឱ្យមេធាវីការពារក្ដី មាស មុត[50]។ ការអនុញ្ញាតត្រូវបានធ្វើឡើងនៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៧[51]។

## *សេចក្ដីពិចារណាផ្សេងទៀត*

29. សំណើនេះគោរពចំពោះសិទ្ធិទទួលបានសវនាការដោយត្រឹមត្រូវយុត្តិធម៌របស់ មាស មុត ដោយសារ វានឹងមិនធ្វើឱ្យមានការពន្យារកិច្ចដំណើរការនីតិវិធីដោយមិនត្រឹមត្រូវនោះឡើយ[52]។ សហ

---

[47] ពាក់ព័ន្ធនឹង **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, កថាខណ្ឌ៥៩-៦១។ **D120** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម, កថាខណ្ឌ១៥-១៧។ **D174** កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង, កថាខណ្ឌ ៤ ៦ និង៨។

[48] លេខឯកសាររបស់មជ្ឈមណ្ឌល DC Cam និង ERNs នៃឯកសារសហកាលិកដែលឆ្លើយឆ្លងនិងគាំទ្រ ត្រូវបានរកឃើញនៅក្នុងជួរ ១៥-២៣ នៃបញ្ជីស-២១ របស់ កសចស។

[49] **D114/230.1.2** បញ្ជីឯកសារ, ៣០ មិថុនា ២០១៦។

[50] សូមមើល *ខាងដើម*, កថាខណ្ឌ៦។

[51] **E442/3/1** ការអនុញ្ញាតលើកទីពីរ។

[52] សំណុំរឿង០០២-**D164/3/6** សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច លើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុក

ព្រះរាជអាជ្ញាទទួលស្គាល់សារៈសំខាន់នៃការធ្វើយ៉ាងណាឱ្យកិច្ចស៊ើបសួរនៃសំណុំរឿង០០៣ ឆាប់ដល់ទីបញ្ចប់។ ការណ៍នេះក៏មានសារៈសំខាន់ចំពោះជនរងគ្រោះដែលនៅរស់រានមានជីវិតផងដែរ ដោយសារពួកគាត់ភាគច្រើនចាស់ៗហើយ ហើយពួកគាត់ក៏ចង់ឃើញកិច្ចស៊ើបសួរត្រូវបានបិទបញ្ចប់ និងការចាប់ផ្តើមសវនាការជំនុំជម្រះកើតឡើងឆាប់ៗតាមដែលអាចធ្វើបាន។ ពួកគាត់ក៏មានសិទ្ធិដែលត្រូវបានបង្កើតឡើងយ៉ាងល្អ ដើម្បីបានដឹងកាន់តែច្រើនរហូតដល់ការពិតពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តប្រឆាំងនឹងពួកគាត់ និងអត្តសញ្ញាណជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត និងដើម្បីដាក់អ្នកដែលទទួលខុសត្រូវទាំងនោះឱ្យទទួលខុសត្រូវ[53]។

30. អាស្រ័យហេតុនេះ សំណើនេះដាក់បញ្ចូលឯកសារពាក់ព័ន្ធបំផុតមួយចំនួនយ៉ាងសមរម្យ ដែលបានជ្រើសរើសចេញពីប្រភពឯកសាររាប់ពាន់ដែលមាននៅលើសំណុំរឿង០០២ តែមិនបង្ហាញនៅលើសំណុំរឿង០០៣។ អាស្រ័យដូចមូលហេតុកត់សម្គាល់ខាងលើ និងរៀបរាប់បន្ថែមក្នុង **ឧបសម្ព័ន្ធ ក** សម្ភារៈដែលបានស្នើសុំ ផ្តល់នូវសេចក្តីពិស្តារដែលមិនទាន់មាននៅលើសំណុំរឿង ឬដែលសំខាន់មិនអាចខ្វះបានសម្រាប់ការយល់ដឹងឱ្យបានច្បាស់លាស់ អំពីភ័ស្តុតាងដែលមាននៅទីនោះរួចហើយ។ **ឧបសម្ព័ន្ធ ក** ផ្តល់នូវសេចក្តីសង្ខេបយ៉ាងពិស្តារដែលខ្លីហើយច្បាស់អំពីសម្ភារៈនិមួយៗ និងភាពពាក់ព័ន្ធរបស់វាដើម្បីជួយសម្រួលដល់ការពិនិត្យចំពោះភាគី និង សចស និងដើម្បីជាកិច្ចខិតខំប្រឹងប្រែងដើម្បីធានាថា ការពិនិត្យមិនមែនជាបន្ទុកហួសហេតុទេ។

## ***ការផ្តល់ឯកសារជូនមេធាវីការពារក្តី មាស មុត***

---

បានការជំនុំជម្រះក្តីនៅក្នុងពេលវេលាសមស្រមមួយ ដូចមានចែងនៅក្នុងមាត្រា១៤ នៃអនុសញ្ញា ICCPR និងវិធាន២១(៤) នៃវិធានផ្ទៃក្នុង)។ សូមមើលផងដែរ **D209** សេចក្តីសម្រេច ចុះថ្ងៃទី១៦ ខែកញ្ញា, កថាខណ្ឌ៩។

[53] សូមមើល ជាឧទាហរណ៍ *រដ្ឋអាជ្ញា ទល់នឹង Katanga និង Chui,* ICC-01/04-01/07-474, អង្គបុរេជំនុំជម្រះ I (ចៅក្រមទោល) "សេចក្តីសម្រេចលើចំនួនសិទ្ធិផ្នែកនីតិវិធីអមនឹងឋានៈផ្នែកនីតិវិធីរបស់ជនរងគ្រោះក្នុងដំណាក់កាលមុនសវនាការនៃរឿងក្តី", ១៣ ឧសភា ២០០៨, កថាខណ្ឌ៣២ និងកំណត់សម្គាល់ជើងទំព័រ ៣៩ ("ផលប្រយោជន៍ស្នូលរបស់ជនរងគ្រោះនៅក្នុងការកំណត់អំពីអង្គហេតុ ការធ្វើអត្តសញ្ញាណកម្មនៃជនទាំងឡាយដែលទទួលខុសត្រូវ និងការប្រកាសអំពីការទទួលខុសត្រូវរបស់ពួកគេ គឺនៅជាឫសគល់នៃសិទ្ធិដែលត្រូវបានបង្កើតឡើងយ៉ាងល្អចំពោះការពិតសម្រាប់ជនរងគ្រោះនៃការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ")។ សូមមើល កថាខណ្ឌ៣៤-៣៦ ("ផលប្រយោជន៍ស្នូលរបស់ជនរងគ្រោះនៅក្នុងការស្វែងរកការពិត អាចនឹងត្រូវបានបំពេញតែក្នុងករណីដែល (i)ជនទាំងឡាយដែលទទួលខុសត្រូវចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មនានាដែលពួកគេបានទទួលរងនូវគ្រោះថ្នាក់ ត្រូវបានប្រកាសថាមានពិរុទ្ធ និង (ii) ជនទាំងឡាយដែលមិនមានការទទួលខុសត្រូវចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មនានាដែល

31. ដូចបានថែងពីខាងលើ[54] និងយោងតាមសេចក្តីសម្រេច ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៦[55] សហព្រះរាជអាជ្ញាបានស្នើសុំ និងបានទទួលការអនុញ្ញាតពីអង្គជំនុំជម្រះសាលាដំបូង ដើម្បីដាក់បង្ហាញឯកសារសម្ងាត់នៃសំណុំរឿង០០២ ដែលបានចុះបញ្ជីក្នុង **ឧបសម្ព័ន្ធ ក** (សម្គាល់ដោយ "C" នៅក្នុងជួរ ២) ជូនក្រុមមេធាវីការពារក្តីនៃសំណុំរឿង០០៣។ ភ្លាមៗមុនការដាក់ជូនសំណើសុំនេះ សហព្រះរាជអាជ្ញាក៏បានផ្តល់ឱ្យមេធាវីការពារក្តី មាស មុត នូវសំណៅអេឡិចត្រូនិកមួយនៃឯកសារសម្ងាត់ទាំងនោះ សម្រាប់គោលបំណងមានកម្រិតនៃការពិនិត្យតែប៉ុណ្ណោះ[56]។ សម្ភារៈដែលនៅសល់ គឺជាសម្ភារៈមិនសម្ងាត់ ហើយដែលគួរតែជាសម្ភារៈដែលមេធាវីការពារក្តី មាស មុត អាចរកបាននៅលើប្រព័ន្ធ Zylab។

## IV. សេចក្តីបញ្ចប់

32. សំណើសុំបំពេញកិច្ចនេះ គឺមានលក្ខណៈជាក់លាក់គ្រប់គ្រាន់ នាំដល់ការបញ្ជាក់អំពីការពិត មានភាពចាំបាច់សម្រាប់កិច្ចស៊ើបសួរ និងមានការគោរពចំពោះសិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយត្រឹមត្រូវយុត្តិធម៌របស់ មាស មុត។ អាស្រ័យមូលហេតុនេះ សហព្រះរាជអាជ្ញាសូមស្នើឱ្យដាក់សម្ភារៈទាំងអស់ដូចបានចុះបញ្ជីក្នុង **ឧបសម្ព័ន្ធ ក** ទៅក្នុងសំណុំរឿង០០៣៕

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៧ | **លោក Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញាអន្តរជាតិ | [stamp: CO-PROSECUTORS CO-PROCUREURS E.C.C.C. C.E.T.C.] | [signature] |

[54] សូមមើល *ខាងដើម*, កថាខណ្ឌ៦។

[55] សូមមើល *ខាងដើម*, កថាខណ្ឌ៤។

[56] ឯកសារសម្ងាត់ដែលអាចឱ្យក្រុមមេធាវីការពារក្តីរកបាននៅលើឃ្លាំងផ្ទុកឯកសាររួម ដូចបានរៀបរាប់យ៉ាងលម្អិតនៅក្នុងសារអេឡិចត្រូនិកដែលបានផ្ញើចេញពីជំនួយការសហព្រះរាជអាជ្ញាម្នាក់នៅម៉ោង៣៖៤៨នាទី រសៀល ថ្ងៃទី០៩ កុម្ភៈ ២០១៧